**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**

**លេខ:០០៧/២៦ ស.ត...... អអរ**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) នាព្រឹកថ្ងៃសុក្រ ១២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ ដោយបានពិភាក្សា និងសម្រេចរបៀបវារៈសំខាន់ៗ ដូចខាងក្រោម៖

### ១- របាយការណ៍បច្ចុប្បន្នភាពនៃវិស័យទេសចរណ៍ និងការជំរុញយុទ្ធនាការទស្សនាកម្ពុជានៅរដូវកាលបៃតង

យោងតាមការវិភាគទៅលើទិន្នន័យជាក់ស្តែង សម្រាប់ឆ្នាំ២០២៦ វិស័យទេសចរណ៍កម្ពុជានៅបន្តស្ថិតក្នុងស្ថានភាពដែលត្រូវប្រឈមនឹងកត្តាខាងក្រៅមួយចំនួន រួមមាន បញ្ហាព្រំដែនកម្ពុជា-ថៃ ការបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ដែលអាចជះឥទ្ធិពលមកលើទំនុកចិត្តនៃការធ្វើដំណើរ និងលំហូរទេសចរអន្តរជាតិមកកម្ពុជា។ ក្នុងបរិបទនេះ វិស័យទេសចរណ៍ត្រូវបានរំពឹងថា នឹងបន្តមានកំណើនយឺត ប៉ុន្តែនៅតែទទួលបានការគាំទ្រយ៉ាងសំខាន់ពីនិន្នាការទេសចរក្នុងស្រុក តាមរយៈការអនុវត្តយុទ្ធនាការ «ទស្សនាកម្ពុជានៅរដូវកាលបៃតង»។ ទន្ទឹមនឹងនេះ វិស័យនេះក៏ត្រូវបានរំពឹងថា នឹងបន្តរក្សាបាននូវភាពធន់ ភាពប្រកួតប្រជែង និងមានសមត្ថភាពក្នុងការឆ្លើយតបនឹងវិបត្តិនានា ដើម្បីបន្តដើរតួនាទីជាសសរស្តម្ភដ៏រឹងមាំមួយនៃសេដ្ឋកិច្ចជាតិ។ ក្នុងរយៈពេល ៥ខែ ឆ្នាំ២០២៦ ទេសចរអន្តរជាតិបានមកទស្សនាកម្ពុជាមានចំនួន ១.៥៣៩.០២៦នាក់ ថយចុះ ៤៧,៨% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៥។ ទេសចរផ្ទៃក្នុង៖ ទេសចរជាតិ បានធ្វើដំណើរកម្សាន្តប្រមាណ ២០.៣០៩.៤៦៣នាក់ កើនឡើង ៥៤,២% និងទេសចរបរទេស ប្រមាណ ១.៦៥៤.០៨៦នាក់ ថយចុះ ១៤,៥% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៥។

ឈរលើមូលដ្ឋាននៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងដើម្បីធានាបាននូវនិរន្តរភាពនៃវិស័យទេសចរណ៍ ក្រសួងទេសចរណ៍បានកំណត់នូវទិសដៅយុទ្ធសាស្ត្រអាទិភាពមួយចំនួន ដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពការងារ រួមមាន ទី១). ការពង្រឹងអភិបាលកិច្ច និងកិច្ចសហប្រតិបត្តិការរួម ទី២). ការធ្វើពិពិធកម្មផលិតផលទេសចរណ៍ តាមរយៈយុទ្ធនាការ «ទស្សនាកម្ពុជានៅរដូវកាលបៃតង» ទី៣). ការពង្រឹងគុណភាពសេវាកម្មនិងធនធានមនុស្ស និង ទី៤). ការធ្វើបរិវត្តកម្មឌីជីថលនិងការបង្កើនប្រសិទ្ធភាពការងារ។

## ២- សេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៥-២០៣០

សេចក្តីព្រាងផែនការសកម្មភាពជាតិនេះ មាន ៧ផ្នែក ត្រូវបានរៀបចំឡើងដោយអនុលោមតាមក្របខ័ណ្ឌជាតិនិងក្របខ័ណ្ឌអន្តរជាតិ ក្នុងគោលបំណងកាត់បន្ថយអំពើហិង្សាលើស្ត្រី រួមទាំងក្រុមដែលមានហានិភ័យខ្ពស់ តាមរយៈការបង្កើតកិច្ចអន្តរាគមន៍ ការបង្ការទប់ស្កាត់ ការបង្កើនការឆ្លើយតប ការទទួលបានសេវាប្រកបដោយគុណភាព និងការសម្របសម្រួលពហុវិស័យនិងកិច្ចសហការ។ សេចក្តីព្រាងផែនការសកម្មភាពជាតិនេះ មានសារៈសំខាន់ក្នុងការបន្តរួមចំណែកអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) ពិធីសារបន្ថែមលើអនុសញ្ញានេះ និងលើលិខិតូបករណ៍អន្តរជាតិ។ ផ្អែកលើក្របខ័ណ្ឌច្បាប់ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងការវាយតម្លៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលនានាពាក់ព័ន្ធការទប់ស្កាត់អំពើហិង្សាលើស្ត្រី ជាពិសេស ការអនុវត្តផែនការសកម្មភាពជាតិនេះ បានបញ្ជាក់ថា ប្រទេសកម្ពុជាបាននិងកំពុងស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ ក្នុងការបំពេញកាតព្វកិច្ចជារដ្ឋភាគីនៃការអនុវត្តអនុសញ្ញា (ស៊ី-ដ) និងលើលិខិតូបករណ៍អន្តរជាតិមួយចំនួន ជាពិសេសការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ ជាទិសដៅ កម្ពុជានឹងបន្តកិច្ចខិតខំប្រឹងប្រែងឱ្យកាន់តែសកម្ម ដើម្បីធានាថា ស្ត្រីត្រូវបានការពារនិងមានសុវត្ថិភាពនៅគ្រប់ទីកន្លែង ព្រមទាំងធានាឱ្យបានថា ស្ត្រីទាំងអស់នឹងរស់នៅក្នុងបរិយាកាសមួយប្រកបដោយភាពថ្លៃថ្នូរ ការអភិវឌ្ឍ ក្តីស្រឡាញ់ និងកិច្ចការពារ សំដៅបញ្ចប់ឱ្យបាននូវអំពើហិង្សាលើស្ត្រីគ្រប់ទម្រង់ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និងឈានទៅសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា នៅត្រឹមឆ្នាំ២០៣០។

## ៣- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីប្រាតិភោគជាអន្តរជាតិចំពោះឧបករណ៍ចល័ត និងពិធីសារនៃអនុសញ្ញាស្តីពីប្រាតិភោគជាអន្តរជាតិចំពោះឧបករណ៍ចល័ត ពាក់ព័ន្ធនឹងករណីជាក់លាក់នៃឧបករណ៍អាកាសយាន

អនុសញ្ញានេះ មាន ១៤ជំពូក និង ៦២មាត្រា ត្រូវបានរៀបចំឡើងដោយអង្គសន្និបាតលើកទី៤២ របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) និងបានចុះហត្ថលេខានៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០១ នៅទីក្រុងខេបថោន ប្រទេសអាហ្វ្រិកខាងត្បូង និងបានចូលជាធរមាន កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០០៦។ គិតត្រឹមខែមិថុនា ឆ្នាំ២០២៦ មានប្រទេសចំនួន ១២៤ បានចូលជារដ្ឋភាគីនៃអនុសញ្ញា និងប្រទេសចំនួន ១០៤ បានចូលជារដ្ឋភាគីនៃពិធីសារអាកាសយាននេះ។ ដោយឡែក កម្ពុជាពុំបានចុះហត្ថលេខាលើអនុសញ្ញានិងពិធីសារអាកាសយាននេះទេ។ ក្នុងក្របខ័ណ្ឌអាស៊ានប្រទេសចំនួន៥ បានចូលជារដ្ឋភាគីនៃអនុសញ្ញានិងពិធីសារអាកាសយាន រួមមាន ប្រទេសម៉ាឡេស៊ី ឆ្នាំ២០០៦ ឥណ្ឌូណេស៊ី ឆ្នាំ២០០៧ សិង្ហបុរី ឆ្នាំ២០០៩ មីយ៉ាន់ម៉ា ឆ្នាំ២០១៣ និងវៀតណាម ឆ្នាំ២០១៥។

ការផ្តល់សច្ចាប័ននៃអនុសញ្ញានិងពិធីសារអាកាសយាននេះ នឹងនាំមកនូវអត្ថប្រយោជន៍សំខាន់ៗ រួមមាន ១). អត្ថប្រយោជន៍ផ្លូវច្បាប់ នឹងជួយឱ្យកាន់តែប្រសើរឡើងថែមទៀតដល់កម្ពុជា ក្នុងការអនុវត្តសិទ្ធិធានារក្សាជាកម្មសិទ្ធិនិងសិទ្ធិជួលចំពោះឧបករណ៍អាកាសយាន ក្រោមរបៀបរបបអន្តរជាតិថ្មីមួយនិងតែមួយ ក្នុងការគ្រប់គ្រងឧបករណ៍ចល័តដែលមានតម្លៃខ្ពស់ ដូចជា តួអាកាសយាន ម៉ាស៊ីនអាកាសយាន និងឧទ្ធម្ភាគចក្រជាដើម ដែលហៅថា

ប្រាតិភោគជាអន្តរជាតិរួម ហើយត្រូវបានទទួលស្គាល់ពីគ្រប់បណ្តារដ្ឋភាគីផ្សេងៗទៀត តាមរយៈការបង្កើតប្រព័ន្ធចុះបញ្ជីអន្តរជាតិជាប្រព័ន្ធអេឡិចត្រូនិក និង ២). អត្ថប្រយោជន៍សេដ្ឋកិច្ច នឹងផ្តល់ជំនឿទុកចិត្តដល់បណ្តាអ្នកវិនិយោគនិងអ្នកឱ្យខ្ចីប្រាក់ក្នុងការផ្តល់ហិរញ្ញប្បទានកាន់តែច្រើនឡើងថែមទៀត ដើម្បីទិញឬជួលឧបករណ៍ចល័តដែលមានតម្លៃខ្ពស់ ដូចជា តួអាកាសយាន ម៉ាស៊ីនអាកាសយាន និងឧទ្ធម្ភាគចក្រជាដើម ដោយសារតែមានប្រាតិភោគជាអន្តរជាតិលើគោលការណ៍អនុវត្តនៃសិទ្ធិកាន់កាប់ឡើងវិញ ការដកបញ្ជី និងការនាំចេញវិញនូវអាកាសយានព្រមទាំងការទូទាត់សំណង។

## ៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក

កិច្ចព្រមព្រៀងនេះ មាន ១៦មាត្រា ត្រូវបានរៀបចំឡើងដើម្បីបង្កើតឱ្យមានអភិក្រមរួមមួយសម្រាប់គ្រប់គណៈកម្មការអាស៊ាន រួមទាំងក្រុមការងារផលិតផលអាស៊ានទាំងអស់ នៅក្រោមគណៈកម្មការពិគ្រោះយោបល់អាស៊ានផ្នែកស្តង់ដានិងគុណភាព ដើម្បីប្រើប្រាស់ជាគោលការណ៍រួម និងជាបន្ទាត់សម្រាប់រៀបចំកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ាននីមួយៗ ដែលខ្លួនទទួលបន្ទុក។

កិច្ចព្រមព្រៀងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា និងបណ្តាសមាជិកអាស៊ាន រួមមាន ១). ផ្តល់នូវមូលដ្ឋានដល់គ្រប់គណៈកម្មការ និងក្រុមការងារអាស៊ានទាំងអស់ប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមក តាមផ្នែកផលិតផលឬសេវាកម្មសម្រាប់ការបង្កើតឱ្យបាននូវទីផ្សារតែមួយអាស៊ាន ២). ផ្តល់នូវមូលដ្ឋានដល់គ្រប់ប្រតិភូរបស់កម្ពុជាប្រើប្រាស់ជាមូលដ្ឋានក្នុងការរក្សាគោលជំហរការពារ ក្នុងការរៀបចំកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកផលិតផលឬសេវាកម្ម ដែលខ្លួនទទួលបន្ទុក ៣). ផ្តល់ជាមូលដ្ឋានសម្រាប់សម្របសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងធ្វើឱ្យមានលំហូរដោយសេរីនូវផលិតផលជាមូលដ្ឋានរបស់អាស៊ាន ៤). ពង្រឹងដល់សមត្ថភាពរបស់អង្គភាពចេញវិញ្ញាបនបត្រ អង្គភាពធ្វើតេស្ត និងអង្គភាពធ្វើអធិការកិច្ចរបស់កម្ពុជា ឱ្យបំពេញស្របតាមគោលការណ៍នៃកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកផលិតផលឬសេវាកម្ម ៥). កាត់បន្ថយការខាតបង់ធនធានរបស់វិស័យឯកជនទៅលើការធ្វើសេវាកម្មផ្តល់វិញ្ញាបនបត្រ តេស្ត និងអធិការកិច្ចឡើងវិញ និង ៦). ជំរុញឱ្យការធ្វើពាណិជ្ជកម្មតាមវិស័យ ឬតាមផ្នែកផលិតផល ឬសេវាកម្មនីមួយៗប្រកបដោយសមធម៌ និងលើកកម្ពស់ភាពប្រកួតប្រជែងដោយសុចរិតនៅកម្ពុជា។

## ៥- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកតាមផ្នែកអាស៊ានសម្រាប់សម្ភារៈអគារនិងសំណង់

កិច្ចសម្រុះសម្រួលនេះ មាន ១៣មាត្រា ត្រូវបានរៀបចំឡើងដើម្បីបង្កើតឱ្យមានអភិក្រមរួមមួយសម្រាប់ក្រុមការងារអាស៊ាន និងគណៈកម្មការចម្រុះអាស៊ាន នៅក្រោមគណៈកម្មការពិគ្រោះយោបល់អាស៊ានផ្នែកស្តង់ដានិងគុណភាពប្រើប្រាស់ជាគោលការណ៍ និងជាបន្ទាត់សម្រាប់រៀបចំសុខដុមនីយកម្មស្តង់ដាអាស៊ាន សុខដុមនីយកម្មបទប្បញ្ញត្តិបច្ចេកទេស និងការរៀបចំនីតិវិធីនៃការទទួលស្គាល់ទៅវិញទៅមកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពអនុលោមរបស់រដ្ឋសមាជិកនីមួយៗ។

កិច្ចសម្រុះសម្រួលនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា និងបណ្តាសមាជិកអាស៊ាន រួមមាន ១). ផ្តល់ជាមូលដ្ឋានសម្រាប់ពង្រឹងនិងសម្របសម្រួលការធ្វើពាណិជ្ជកម្ម និងធ្វើឱ្យមានលំហូរដោយសេរីនូវផលិតផលនៅក្នុង

ទីផ្សារអាស៊ាន ២). ពង្រឹងដល់សមត្ថភាពរបស់អង្គភាពចេញវិញ្ញាបនបត្រ អង្គភាពធ្វើតេស្ត និងអង្គភាពអធិការកិច្ចរបស់កម្ពុជា ឱ្យបំពេញស្របតាមគោលការណ៍នៃកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកអាស៊ានតាមផ្នែកសម្រាប់សម្ភារៈអគារនិងសំណង់ ៣). កាត់បន្ថយការខាតបង់ធនធានរបស់វិស័យឯកជនទៅលើការធ្វើសេវាកម្មផ្តល់វិញ្ញាបនបត្រ តេស្ត និងអធិការកិច្ចឡើងវិញសម្រាប់សម្ភារៈអគារនិងសំណង់ និង ៤). ជំរុញឱ្យការធ្វើពាណិជ្ជកម្មសម្ភារៈអគារនិងសំណង់នៅក្នុងទីផ្សារអាស៊ានប្រកបដោយសមធម៌ និងលើកកម្ពស់ភាពប្រកួតប្រជែងដោយសុចរិតនៅកម្ពុជា។

## ៦- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកអាស៊ានស្តីពីប្រភេទអនុម័តបញ្ជាក់សម្រាប់ផលិតផលយានយន្ត

កិច្ចសម្រុះសម្រួលនេះ មាន ២០មាត្រា ត្រូវបានរៀបចំឡើងដើម្បីបង្កើតឱ្យមានអភិក្រមរួមសម្រាប់ក្រុមការងារអាស៊ាន និងគណៈកម្មការអាស៊ានផ្នែកយានយន្ត ដែលនៅក្រោមគណៈកម្មការពិគ្រោះយោបល់អាស៊ានផ្នែកស្តង់ដានិងគុណភាព ប្រើប្រាស់ជាគោលការណ៍ និងជាបន្ទាត់សម្រាប់រៀបចំសុខដុមនីយកម្មស្តង់ដាអាស៊ាន សុខដុមនីយកម្មបទប្បញ្ញត្តិបច្ចេកទេស និងការរៀបចំនីតិវិធីនៃការទទួលស្គាល់ទៅវិញទៅមកនូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពអនុលោមរបស់រដ្ឋសមាជិកនីមួយៗ។ កិច្ចសម្រុះសម្រួលនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា និងបណ្តាសមាជិកអាស៊ាន ដូចជា ១). ផ្តល់ជាមូលដ្ឋានសម្រាប់ពង្រឹងនិងសម្របសម្រួលការធ្វើពាណិជ្ជកម្ម និងធ្វើឱ្យមានលំហូរដោយសេរីនូវផលិតផលយានយន្តនៅក្នុងទីផ្សារអាស៊ាន ២). ពង្រឹងសមត្ថភាពរបស់អង្គភាពចេញវិញ្ញាបនបត្រ អង្គភាពធ្វើតេស្ត និងអង្គភាពធ្វើអធិការកិច្ចរបស់កម្ពុជាឱ្យបំពេញស្របតាមគោលការណ៍នៃកិច្ចសម្រុះសម្រួលទទួលស្គាល់ទៅវិញទៅមកអាស៊ានតាមផ្នែកសម្រាប់ផលិតផលយានយន្ត ៣). កាត់បន្ថយការខាតបង់ធនធានទៅលើការធ្វើសេវាកម្មផ្តល់វិញ្ញាបនបត្រតេស្ត និងអធិការកិច្ចឡើងវិញទៅលើផលិតផលយានយន្ត និង ៤). ជំរុញឱ្យការធ្វើពាណិជ្ជកម្មផលិតផលយានយន្តនៅក្នុងទីផ្សារអាស៊ានប្រកបដោយសមធម៌ និងលើកកម្ពស់ភាពប្រកួតប្រជែងដោយសុចរិតនៅកម្ពុជា។

## ៧. បញ្ហាផ្សេងៗ

- **សម្តេចធិបតី** បានក្រើនរម្លឹកឱ្យអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវបន្តបង្ក្រាបការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Scam Online) ដោយមិនត្រូវបន្ធូរដៃឡើយ។ បើទោះបីជា **សម្តេច** បានកត់សម្គាល់ពីលទ្ធផលគួរឱ្យពេញចិត្តចំពោះប្រតិបត្តិការនេះ ដែលធ្វើឱ្យអន្តរជាតិទទួលស្គាល់ថា កម្ពុជាបាននិងកំពុងបង្ក្រាប Scam Online យ៉ាងសកម្មក៏ដោយ **សម្តេចធិបតី** នៅតែចេញបទបញ្ជាយ៉ាងម៉ឺងម៉ាត់ចំពោះអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ឱ្យបន្តបេសកកម្មនេះជានិច្ច ដោយដាច់ខាតមិនអនុញ្ញាតឱ្យបញ្ហានេះកើតមាននៅលើទឹកដីកម្ពុជាទៀតឡើយ។

- **សម្តេចធិបតី** បានណែនាំឱ្យអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រួតពិនិត្យនិងគ្រប់គ្រងឱ្យបានចំពោះទំនិញគេចពន្ធនិងទំនិញខូចគុណភាព ហើយត្រូវសហការគ្នាចាត់វិធានការឱ្យបានច្បាស់លាស់ ដោយស្មើភាពនិងតម្លាភាពជាពិសេសដោយផ្តោតលើដើមខ្សែ ពោលគឺអ្នកដែលនាំចូល និងចែកចាយ។ វិធានការនេះត្រូវធ្វើឡើងទាំងមុខទំនិញជាគ្រឿងឧបភោគបរិភោគ ពីព្រោះវាប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និងទាំងទំនិញដែលមានតម្លៃខ្ពស់ពីព្រោះវាប៉ះពាល់ដល់ការប្រកួតប្រជែងដោយស្មើភាព។ ទន្ទឹមនឹងនេះ **សម្តេចធិបតី** ក៏បានណែនាំឱ្យអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្សព្វផ្សាយព័ត៌មានច្បាស់លាស់ជូនប្រជាពលរដ្ឋឱ្យបានជ្រាប និងបានលឿនហ័សអំពីវិធានការរបស់ខ្លួន ដើម្បីចៀសវាងការយល់ច្រឡំ និងមានការបកស្រាយខុសពីគោលបំណងពិត។

- **សម្តេចធិបតី** បានណែនាំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធត្រៀមឆ្លើយតបជាមួយបាតុភូតធម្មជាតិ El Niño ដែលប្រទេសកម្ពុជាកំពុងទទួលរងឥទ្ធិពល។ **សម្តេច** បានណែនាំឱ្យក្រសួងធនធានទឹកនិងឧតុនិយម សហការជាមួយរដ្ឋបាលរាជធានី ខេត្ត បន្តតាមដានការវិវត្តន៍និងផ្សព្វផ្សាយជូនប្រជាពលរដ្ឋបានដឹងអំពីផលវិបាកនៃការប្រែប្រួលអាកាសធាតុនេះ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ត្រៀមមធ្យោបាយចាំបាច់ដើម្បីអន្តរាគមន៍ជួយសង្គ្រោះប្រជាពលរដ្ឋក្នុងករណីចាំបាច់។ ចំណែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រៀមបំរុងស្បៀងនិងសម្ភារៈនានា ជួយអន្តរាគមន៍ដល់ប្រជាកសិករដែលនឹងរងផលប៉ះពាល់ឱ្យបានទាន់ពេលវេលា៕

ថ្ងៃសុក្រ ១២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦